# ចារឹកលើវត្ថុលោហៈក្នុងរាជ្យព្រះបាទជ័យវរ្ម័ទី៧ (ភាគ២)

## ២- ចារឹកលើភាជន៍សំរិទ្ធ K. ១០៥៩

ចារឹកខ្ទីនេះ ចារលើភាជន៍លោហៈ (ចាន ឬ ផ្តិតសំរិទ្ធ) រកឃើញនៅទីតាំងជាមួយចារឹក K. ១០៥៣ គឺជាអតីតអារោគ្យសាលា ឬ មន្ទីរពេទ្យ ក្នុងរាជ្យព្រះបាទជ័យវរ្ម័ទី៧ ពោលគឺនៅស្ថានីយ៍បុរាណវិទ្យាលេខ១១ ស្ថិតនៅបរិវេណក្រុងព្រះរថ ដងស្រីមហាពោធិ៍ ឃុំគោកប៉ិប ស្រុកស្រីមហោសថ (ព័ត៌មានដើមថា ស្រុកស្រីមហាពោធិ៍) ខេត្តប្រាចីនបុរី ប្រទេសថៃ។ បច្ចុប្បន្ន វត្ថុនេះរក្សាទុកនៅក្នុងសារមន្ទីរខេត្តប្រាចីនបុរី ប្រទេសថៃ។ ភាជន៍នេះ មានកម្ពស់ ៧ ស.ម. ទទឹង ១៨ ស.ម. និងបរិមាត្រ ៥៩ ស.ម.។

ចារឹកនេះ សិក្សាដំបូងដោយលោក ហ្សង់ ប៊័រស៊េលីយ៉េរ (Jean Boisselier) នៅក្នុងឆ្នាំ ១៩៧២ ក្នុងអត្ថបទស្តីអំពី កិច្ចបេកសកម្មបុរាណវិទ្យាបារាំងនៅប្រទេសថៃ[១]។ បន្ទាប់មក នៅប្រទេសថៃ ក៏មានការសិក្សាអំពីចារឹកនេះដូចគ្នា និងមាននៅលើគេហទំព័ររបស់មជ្ឈ-មណ្ឌលជាតិពន្ធុវិទ្យាសិរិនថនផងដែរ[២]។

ចារឹកខ្ទីនេះ ចារប្រាប់ពីភាជន៍សំរិតនេះ ជាតង្វាយរបស់មន្ត្រីម្នាក់មានងារនិងឈ្មោះថា «គម្តែងអញស្រីវីរេន្ទ្រាធិបតីវម៌្ម» ថ្វាយចំពោះទេព «គម្តែងជគតស្រីវីរេស្វរ» នៅតំបន់ «សំរោក» ក្នុងមហាសករាជឆ្នាំ ១១០៩ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ១១៨៧។

ក្នុងសិលាចារឹកខ្ទីនេះ មានការគួរកត់សម្គាល់មួយចំនួនលើផ្នែកអក្ខរាវិរុទ្ធ និងស្ថាននាម។ ចំពោះអក្ខរាវិរុទ្ធ សង្កេតឃើញមានពាក្យចំនួនពីរគឺ «វិរេស្វរ» និង «សក» ដែលតាមទម្លាប់ក្នុងសិលាចារឹកដទៃៗធ្លាប់ជួបប្រទះកន្លងមក គឺគួរតែមានអក្ខរាវិរុទ្ធតាមបែបសំស្ក្រឹតជា «វីរេឝ្វរ» ដ្បិតជាពាក្យបង្កើតមកពី «វីរ» ផ្សំនឹង «ឦឝ្វរ» ។ ចំណែកឯពាក្យ «សក៑» ក៏ច្រើនតែប្រទះសំណេរជា «ឝក»។ ចំពោះបញ្ហានេះ បង្ហាញពីការចាប់ផ្តើមក្នុងការប្រែ

---

[១] សូមអានបន្ថែម៖ Boisselier, 1972។

[២] សូមអានបន្ថែម៖ https://db.sac.or.th/inscriptions/inscribe/detail/443 ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ប្រួលសំណេរពីបែបសំស្ក្រឹតមកជាសំណេរបែបខ្មែរ ពោលគឺបង្ហាញពីការធ្លាក់ចុះនៃការប្រើតួអក្សរ «គ» មកប្រើតួអក្សរ «ស»។ ក្នុងចារឹកតែមួយនេះ ពាក្យ «គ្រី» នៅតែប្រើតួអក្សរ «គ» ដដែល។ ម្យ៉ាងសំណេរ «សក៊» ដែលដាក់សញ្ញាវិរាមនៅលើអក្សរ «ក» នេះ ក៏អាចជាកស្តុតាងស្តីពី ឯកព្យាង្គនីយកម្ម លើពាក្យសំស្ក្រឹតផងដែរ។ «គក» ក្នុងពាក្យសំស្ក្រឹតត្រូវអានពីរព្យាង្គថា (គៈ-កៈ)។ តាមរយៈសំណេរ «សក៊» ទំនងជាអានតែមួយព្យាង្គថា (ស័ក/សាក់) (?) ដ្បិតតួនាទីរបស់សញ្ញាវិរាម គឺបង្ហាញថាព្យញ្ជនៈដែលមានវិរាម ជាព្យញ្ជនៈសុទ្ធ ពុំមានស្រៈ និងជាព្យញ្ជនៈប្រកបផងដែរ។

ឯតួអក្សរវិញ ឃើញថាមានទម្រង់ជាអក្សរជ្រៀង ដែលខុសប្លែកពីតួអក្សរជ្រុង ដែលឃើញភាគច្រើនប្រើសម្រាប់តែចារឹករបស់ព្រះមហាក្សត្រ។ ដូច្នេះ តួអក្សរទាំងពីរនេះ មានចរិតប្រើប្រាស់ផ្សេងគ្នា នៅក្នុងរជ្ជកាលព្រះបាទជ័យវម៌្មទី៧។ តួអក្សរជ្រៀងសម្រាប់មន្ត្រី(និងមហាជនទូទៅ?)ប្រើប្រាស់ ឯតួអក្សរជ្រុង សម្រាប់ព្រះមហាក្សត្រប្រើប្រាស់ជាផ្លូវការ។

ឥឡូវនេះ ត្រឡប់មកចាប់អារម្មណ៍ស្ថាននាមនៅក្នុងចារឹកនេះវិញ ឃើញមានពាក្យ «សំរោក» ដែល ធ្លាប់ជួបប្រទះនៅក្នុងសិលាចារឹកជាច្រើន ដែលបង្ហាញថាពាក្យនេះ គឺជាស្ថាននាមផង និងជានរនាមផង។ ខាងក្រោមនេះ គឺជាដំណាក់ស្រង់ព័ត៌មានពាក្យ «សំរោក» នៅក្នុងសិលាចារឹកនានាៈ

**ស្ថាននាម**

- សិលាចារឹកទួលប្រាសាទ (K. ៧២) ស.រ.ទី១០-១១ បានបង្ហាញពី «លោញឥន» ជាមេទ័ពម្នាក់(សេនាបតី)នៅតំបន់សំរោក។
- សិលាចារឹកប្រាសាទបាសែត (K. ២០៦) មហាសករាជ៩៦៤ បង្ហាញពី «ខ្លោញពល»(មេកងទ័ព)ម្នាក់មកពីតំបន់សំរោក ជាអ្នកចូលរួមចារសិលាចារឹកនៅប្រាសាទបាសែត។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## នរនាម

- សិលាចារឹកនៅសំបូរព្រៃគុក (K. ៦០៧) ស.វ.ទី៧ បង្ហាញពីអ្នកបម្រើស្រីម្នាក់ឈ្មោះ «សំរោក» (កុសំរោក៑)។
- សិលាចារឹកវត្តសំបួរមាស (K. ៦៦៤) ស.វ.ទី៧-៨ បង្ហាញពីមន្ត្រីម្នាក់ឈ្មោះ «សំរោក» (ក្មោញ៑សំរោក៑)។
- សិលាចារឹកពពេល (K. ៧១៩) ស.វ.ទី៧ បង្ហាញថាពាក្យនេះ ជាឈ្មោះអ្នកបម្រើប្រុសម្នាក់ (វាសំរោក៑)។
- សិលាចារឹកប្រាសាទបាយ័ន (K. ២៩៣-៥) ស.វ.ទី១២-១៣ បង្ហាញថាពាក្យនេះ ជាព្រះនាមរបស់ទេពមួយអង្គ ដែលទំនងជាអតីតមហាក្សត្រមួយអង្គ(?) (កម្រតេង៑ជគត៑វ្រះបាទសំរោក៑)។

ពាក្យ «សំរោក» នៅក្នុងសិលាចារឹកនេះ មានសំណង់ឃ្លាបញ្ជាក់បានថាជាទីតាំងឬជាស្ថាននាមមួយកន្លែង។ ទីតាំងនេះ ពុំទាន់ដឹងច្បាស់ថានៅទីណាប្រាកដនោះឡើយ។ តើទីតាំងនេះ ត្រូវនឹងទីតាំងរកឃើញភាជន៍សំរិទ្ធនេះ ឬនៅតំបន់ក្បែរៗនេះ?

## អត្ថបទជាអក្សរខ្មែរទំនើប

១- (ជំនូន)វ្រះកម្រតេង៑អញ៑ឝ្រីវីរេន្ទ្រាធិបតិវម៌្មតកម្រតេង្ជគត៑ឝ្រីវីរេឝ្វរនាសំរោក្ត ១១០៩សក៑ ०

## អត្ថបទសម្រួលជាភាសាខ្មែរទំនើប

ជំនូន(របស់)កម្តែងអញស្រីវីរេន្ទ្រាធិបតីវម៌្ម(ថ្វាយ)ចំពោះកម្តែងជគតស្រីវីរេស្វរនៅឯសំរោកក្នុងមហាសករាជ(ឆ្នាំ)១១០៩៕

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ឯកសារយោង

Boisselier, J.

(1972). Travaux de la mission archéologique française en Thaïlande (juillet-novembre 1966). Arts asiatiques, 25, 27-90.

## វែបសាយ

https://db.sac.or.th/inscriptions/inscribe/detail/443

## បញ្ជីរូបភាព




ទូតាំងបង្ហាញភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង




រូបថតភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)




រូបថតភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង




រូបថតភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)




រូបថតភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង




រូបថតភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)




រូបថតភាជន៍លោហៈមានចារឹក K. ១០៥៥ (រូបថត៖ Prachin Buri National Museum)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង